Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១១ដុល្លារ
- ធានា មើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

## ព័ត៌មានសំខាន់ៗខាងក្នុង...

**បាតុករសង្គ្រោះជាតិនៅ"ត្រូកាដេរ៉ូ"ប្រទេសបារាំង**

*សូមអាននៅទំព័រទី ០២*



**លទ្ធផលនៃការបោះឆ្នោតតំបន់ ទី៤កញ្ញា ២០១៨**

*សូមអាននៅទំព័រទី ០៦*




**រឿងប្រលោមលោក "រឿងកុមារយោធិន"**

*សូមអាននៅទំព័រទី ១១*




**បើប្រៀបធៀបកម្ពុជាបច្ចុប្បន្នទៅនឹងរបប ប៉ុល ពត**

*សូមអាននៅទំព័រទី ១៥*



# ទោះជាដោះលែង កឹម សុខា ការរំជើបរំជួលនៅតែមាន







ដោយខ្មែរផុសស.រ.អា.

ប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា បានត្រូវគេមើលឃើញថា"បានទទួលការដោះលែង"ពីពន្ធនាគារត្រពាំងខ្លុង, តែតាមពិតជាការជាការរក្សាឱ្យនៅ"ឃុំខ្លួននៅផ្ទះ"ទៅវិញសោះ។ នៅពេលមុននឹងចេញពីពន្ធនាគារនៅម៉ោង៣ទៀបភ្លឺ នៃថ្ងៃអាទិត្យទី៩កន្លងទៅលោក កឹម សុខា បានបង្ហាញនូវការព្រួយបារម្ភពីសុវត្ថិភាពរបស់លោកជាមួយនឹងលិខិតរបស់លោកផ្ញើរទៅអយ្យការតុលាការ" សូមឱ្យជួយការពារសុវត្ថិភាព" របស់លោកដោយអនុគ្រោះ។

ចំណែកលោក សម រង្ស៊ី ច្របូកច្របល់នឹងដំណែងជាច្រើននៃចលនាសង្គ្រោះជាតិនៅក្រៅប្រទេសមិនបានដឹងជាមុននូវការដោះលែងដ៏សំខាន់មួយ នៅ៤ម៉ោងបន្ទាប់ពីរាត្រីជួបជុំសមាជិករបស់លោកនៅឡូវែលនេះទេ ។ លោក សម រង្ស៊ី នៅតែទាមទារ ឱ្យមានការដោះលែង កឹម សុខា នៅឡើយ ខណៈពេលដែល"ហ្វេស្រនូ"នៅភ្នំពេញឯណោះបានផ្សាយព័ត៌មាននេះតាំងពីព្រលប់មកម្ល៉េះ។

គណបក្សសង្គ្រោះជាតិនៅឡូវែល នាថ្ងៃអាទិត្យបន្ទាប់មកនៅតែប្រកាសធ្វើបាតុកម្មរបស់ខ្លួន នាថ្ងៃទី២៩កញ្ញា បើទោះជាមានការបញ្ចេញលោក កឹម សុខា ពីពន្ធនាគារក៏ដោយ ។

(អានបន្តនៅទំព័រ១០)

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com



ឱសថស្ថាន សេនធូរី
CENTURY PHARMACY
ផ្តល់នូវសេវាកម្មពិសេស និងផ្តោតលើតំរូវការរបស់អតិថិជនម្នាក់ៗ
ថ្នាំពេទ្យមានប្រសិទ្ធភាពស្របតាមវេជ្ជបញ្ជា
វេចខ្ចប់ដោយប្លាស្ទិក
ដឹកជញ្ជូនដោយឥតគិតថ្លៃក្នុងឡូវែល, ឆែមហ្វឺត, ទឹងប្បូរ, តេសប៊ូរី, ដ្រាចេត, ឡូវ៉ិន
ងាយស្រួលក្នុងការផ្ទេរវេជ្ជបញ្ជាពីឱសថស្ថានមួយទៅឱសថស្ថានផ្សេងទៀត
មានជំនួយការខាងឱសថជនជាតិខ្មែរ
www.centuryrx.net
937 Gorham Street • Lowell, MA 01852
978-455-6554 • Fax: 978-455-9476

# បាតុករសង្គ្រោះជាតិនៅ“ត្រូកាដេរ៉ូ”ប្រទេសបារាំង

ដោយ ពិន សំខុន

យើងបានមកដល់ទីលាន"ត្រូកាដេរ៉ូ"នៃសារមន្ទីរសិទ្ធមនុស្សទីក្រុងប៉ារីស នៅម៉ោង២រសៀលនៃថ្ងៃសៅរ៍ទី១ឧសភាកន្លងទៅ, នៅពេលដែលបាតុករគណបក្សសង្គ្រោះជាតិនឹងសាធារណជនប្រមាណជាង២០០នាក់ មានរួមទាំងព្រះសង្ឃផង, បានមកជួបជុំគ្នា នៅទីលាន"ត្រូកាដេរ៉ូ"នោះដើម្បីសម្តែងមតិប្រឆាំងនឹងរបបលោក ហ៊ុន សែន ដែលទើបនឹងបានរៀបចំការបោះឆ្នោតក្លែងក្លាយមួយ ហើយបំរុងនឹងតែងតាំងរដ្ឋាភិបាលថ្មីរបស់ខ្លួន, បានប្រឆាំងនឹងការចាប់ប្រធានរបស់ពួកគេ លោក កឹម សុខា យកទៅដាក់ពន្ធនាគារ តាំងពី១ឆ្នាំមកហើយ,នឹងបានប្រឆាំងការរំលាយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំបង្អស់មួយនៅកម្ពុជា កាលពីឆ្នាំមុនដូចគ្នា។

មកពីតំបន់ជាច្រើននៃប្រទេសបារាំង បាតុករបានលើកបង្ហាញផ្ទាំងបដារធំតូច សរសេរជាភាសាបារាំងនឹងខ្មែរ នៅពីមុខសាធារណជនបារាំងបាតុករនឹងសាស្ត្រដ៏ទៃ ដែលដើរខ្វាត់ខ្វែងពេញទីធ្លា, បាតុករគណបក្សសង្គ្រោះជាតិ"គណកម្មការយុត្តិធមិសម្រាប់ខ្មែរ"នឹង"គណបក្សខ្មែរឈប់ក្រ"បានស្រែកជ័យឃោសន៍ សម្តែងមតិជាអាទិ៍"ហ៊ុន សែន ត្រូវដោះលែងលោក កឹម សុខា..." មិនទទួលស្គាល់ការបោះឆ្នោតក្លែងក្លាយ "យើងគាំទ្រកាអនុវត្តនិកិច្ចព្រមព្រៀងក្រុងប៉ារីសនៅកម្ពុជា" មានខ្លះគូរគំនូរថ្លុកបង្ហាញពី" ហ៊ុន សែន អង្គុយឃ្លោងលើជញ្ជីងយុត្តិធម៏នៅកម្ពុជា... ។ល។ អតីតសមាជិកសភាគណបក្សសង្គ្រោះជាតិ៣រូប បានមកចូលរួមបាតុកម្ម គឺលោក ញ៉ែម ប៉ុញ្ញារិទ្ធ - លោក លឹម គឹមយ៉ា (កំពុងធំ) - លោក ទូន គើត (ព្រៃវែង) - រួមទាំងសកម្មជនជាច្រើនទៀត មានជាអាទិ៍លោក ហាម ប៊ុនឆាយ លោកប៉ែន វ៉ាណ្ណូ លោក ម៉ាប៊ុន អ្នកស្រី ចំរើន លោក ឌិត សារីក លោក ចយ ចាន់ថា -មានទាំងព្រះសង្ឃច្រើនអង្គ ក៏មាននិមន្តចូលរួមដែរ។ ជួបសម្ភាសន៏ជាមួយបាតុករថ្នាក់ដឹកនាំមួយចំនួននៅទីលាន"ត្រូកាដេរ៉ូ" យើងបានទទួលការវិនិច្ឆ័យស្ថានភាពនយោបាយកម្ពុជាដូចតទៅ...:

លោក ហាម ប៊ុនឆាយ ជាប្រធានគណកម្មការរៀបចំបាតុកម្មគណបក្សសង្គ្រោះជាតិបាននិយាយថា"ធ្វើបាតុកម្មដើម្បីគាំទ្រអន្តរជាតិឱ្យដាក់សម្ពាតលើលោក ហ៊ុន សែន ឱ្យត្រឡប់មករកកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១វិញ-ឱ្យមានការដោះលែងលោក កឹម សុខា ហើយធ្វើឱ្យអ្វីៗ ឱ្យត្រឡប់មករកសភាពដើមវិញ... "លោក ហាម ប៊ុនឆាយ មានជំនឿថា"សម្ពាតអន្តរជាតិ នឹងមានប្រសិទ្ធិភាពហើយប្រជាពលរដ្ឋខ្មែរនឹងបានរំដោះចេញពីគ្រោះថ្នាក់ដល់ជីវិតជាតិ"បាន។

លោកញ៉ែមប៉ុញ្ញារិទ្ធតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិលោកបាននិយាយថា "ស្ថានភាពនយោបាយនៅកម្ពុជាបន្ទាប់ពីលោក ហ៊ុន សែន ធ្វើការបោះឆ្នោតរួច កាន់តែចង្អៀតនឹងដុនដាបទៅ ទោះជាខាងផ្នែកកិច្ចការបរទេសក៏ដូចកិច្ចការសង្គម-ប្រជាពលរដ្ឋនឹងសហគមន៏អន្តរជាតិបានមើលឃើញថា មិនមានភាពធូស្រាលទេខាងសេដ្ឋកិច្ចក៏ដូចជាបញ្ហាសង្គមនោះ ដូច្នេះត្រូវតែមានដំណោះស្រាយដោយយកសន្ធិសញ្ញាក្រុងប៉ារីសឡើងមកវិញដោយមិនបាច់មានការចរចារអ្វីក្រៅតែពីដោះលែងលោក កឹម សុខា- ដោយអនុញ្ញាត្តិឱ្យគណបក្សប្រឆាំងដ៏ធំតែមួយនេះត្រឡប់មកវិញ...ខ្ញុំជឿថាជាមួយនឹងបាតុកម្មនេះ សហគមន៏អន្តរជាតិនឹងមើលឃើញថា ប្រជាពលរដ្ឋខ្មែរទាំងក្នុងនឹងក្រៅប្រទេសចង់បានអ្វីសម្រាប់ប្រទេសរបស់ខ្លួន? គេមិនមានឃើញថាគណបក្សយើងបែកបាក់គ្នាអ្វីទេ យើងនាំគ្នាចេញទៅជួបក្រសួងការបរទេសប្រទេសផ្សេងៗ តាមកម្មវិធីខុសៗគ្នារបស់លោកជំទាវ មូរ សុខហួរ ក៏ដូចជាកញ្ញា កឹម មនោវិទ្យា គឺបានលទ្ធផលរួមសម្រាប់សង្គ្រោះជាតិ ចំណែកការបង្កើតជាអង្គការឬក្រុមឈ្មោះផ្សេងៗនោះ ជាសិទ្ធរបស់សមាជិកម្នាក់ៗ ខ្ញុំមិនអាចហាមឃាត់នរណាបានទេ...។

លោកលឹម គឹមយ៉ា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិតំបន់កំពុងធំ លោកបានទៅភ្នំពេញនៅខែមិថុនា មុនពេលបោះឆ្នោតលោកបានពិព័តិនាថា "មុនពេលបោះឆ្នោត ជាពិសេសខាងគណបក្សសង្គ្រោះជាតិប្រជាពលរដ្ឋបានត្រូវអាជ្ញាធរតាមដានមិនឱ្យមានការជួបជុំគ្នា បង្ហាញនូវការគុំគួននៅពេលខ្លួនត្រូវការក្រដាស់ស្នាមពីអាជ្ញាធរគម្រាមកំហែងប្រសិនបើមិនទៅបោះឆ្នោត, នៅពេលបោះឆ្នោតមានការបង្ខិតបង្ខំឱ្យចេញទៅបោះឆ្នោត ហើយលទ្ធផលដែលចេញមកឃើញមានប្រជាពលរដ្ឋលើស៧៥ភាគរយទៅបោះឆ្នោតឃើញថាមិនសមរម្យទេ ពីព្រោះលើកមុនសោះ គែបោះឆ្នោតឱ្យតែ៤០=៤៥%ទេ ឥឡូវស្រាប់តែឡើងជាង៧៥%មិនអាចទៅកើតទេ។ ការបោះឆ្នោតកន្លងទៅនេះប្រជាពលរដ្ឋមិនបានទៅបោះឆ្នោតឱ្យគណបក្សដែលខ្លួនស្រឡាញ់ចូលចិត្តទេ គឺប្រឆាំងនឹងឆន្ទះប្រជាពលរដ្ឋទាំងស្រុង...។





ព្រះតេជគុណ អ៊ឹង សុខ

លោក ទូត គឿត តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និយាយថា "ខ្ញុំមកនេះចង់បង្ហាញពីឆន្ទៈថា នៅជាមួយប្រជាពលរដ្ឋខ្មែរ កន្លះនគរ ដែលមានការស្រឡាញ់គណបក្សសង្គ្រោះជាតិជាប់នឹងបេះដូងទៅហើយ មិនអាចដកចេញបានទេ... ប្រសិនបើមានគេយល់ថា ខ្មែរបែកបាក់គ្នា គឺគ្រាន់តែធ្វើសកម្មភាពខុសគ្នា តែគោលដៅដូចគ្នា ដែលនេះហើយហៅថា ប្រជាធិបតេយ្យ... ខ្ញុំនៅចាំថា លោកប្រធាន កឹម សុខា តែងនិយាយថា យើងមិនត្រូវយកខ្មែរនាជាសត្រូវ ដូច្នេះខ្ញុំយល់ថាខ្មែរនៅទីណាក៏អាចនិយាយគ្នាត្រូវគ្នាបានដែរ... យើងចូលរួមបាតុកម្មថ្ងៃនេះ គឺយើងចង់បង្ហាញពីភាពរួបរួមគ្នានេះ ដើម្បីទាមទារពីអំណាចផ្តាច់ការ ហ៊ុន សែន ឱ្យដោះលែងលោកប្រធាន កឹម សុខា រៀបចំប្រទេសឱ្យមានប្រជាធិបតេយ្យឡើងវិញ យើងនឹងនាំគ្នាទាមទារជាបន្តរបន្ទាប់ រហូតទាល់ទេបានសម្រេច...។

លោក ប៉ែន វ៉ាណ្ណូ ជាអគ្គលេខាធិការគណបក្ស"ខ្មែរឈប់ក្រ"បានវាយតម្លៃការគ្រប់គ្រង

តទៅទំព័រទី ១៤







លោក ហាម ប៊ុនឆៃ


លោក ប៉ែន វ៉ាន់ណូ


លោក ទូត គឿន និងលឹម គឹមយ៉ា


លោក ញ៉ែម ប៉ុញ្ញារិទ្ធ

# ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យ ត្រាស់បង្គាប់តែងតាំងសមាសភាពគណៈរដ្ឋមន្ត្រីថ្មី ក្រោយទទួលបានការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តពីរដ្ឋសភា

ភ្នំពេញៈ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្តមសីហមុនីព្រះមហាក្សត្រនៃកម្ពុជា នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨នេះ បានចេញព្រះរាជក្រឹត្យត្រាស់បង្គាប់តែងតាំងសមាសភាពគណៈរដ្ឋមន្ត្រីសម្រាប់អាណត្តិថ្មី ក្រោយទទួលបានការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តពីរដ្ឋសភា និងចូលស្បថកាន់តំណែង។

គណៈរដ្ឋមន្ត្រីអាណត្តិថ្មី មានសម្ដេចតេជោ ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រីអមដោយឧបនាយករដ្ឋមន្ត្រីចំនួន១០រូប ទេសរដ្ឋមន្ត្រីចំនួន១៧រូប និងរដ្ឋមន្ត្រីចំនួន២៩រូប។ សមាសភាពរាជរដ្ឋាភិបាលអាណត្តិទី០៦នេះ មិនមានរដ្ឋលេខាធិការដូចអាណត្តិទី០៥ទេ។ ឧបនាយករដ្ឋមន្ត្រីត្រូវបានដំឡើងថ្មីចំនួន៣រូប រួមមាន លោក ប្រាក់ សុខុន, លោក អូន ព័ន្ធមុនីរ័ត្ន និងលោក ជា សុផារ៉ា។ ចំណែកទេសរដ្ឋមន្ត្រីកើនពី១៥នាក់ទៅ១៧នាក់ ។

ខាងក្រោមនេះជាព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រៈ

## ព្រះរាជក្រឹត្យ

នស/រកត/០៩១៨/៩២៥

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៨/៨៦២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បញ្ចប់តំណែងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ព្រមទាំងរាល់ព្រះរាជក្រឹត្យ ស្ដីពីការកែសម្រួលសមាជិករាជរដ្ឋាភិបាលជាបន្តបន្ទាប់ មុនថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ និងតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ដូចតទៅ៖

**I-នាយករដ្ឋមន្ត្រី**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

**II-ឧបនាយករដ្ឋមន្ត្រី**

១- សម្ដេចក្រឡាហោម ស ខេង
២- សម្ដេចពិជ័យសេនា ទៀ បាញ់
៣- ឯកឧត្តម ហោ ណាំហុង
៤- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន
៥- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ប្រចាំការ

១

៦- ឯកឧត្តម យឹម ឆៃលី
៧- ឯកឧត្តម កែ គឹមយ៉ាន
៨- ឯកឧត្តម ប្រាក់ សុខុន
៩- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
១០- ឯកឧត្តម ជា សុផារ៉ា

**III-ទេសរដ្ឋមន្ត្រី**

| | |
|---|---|
| ១- ឯកឧត្តម ឆាយ ថន | |
| ២- ឯកឧត្តម ប៉ុល សាហ៊ឿន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៣- ឯកឧត្តម គន់ គីម | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៤- ឯកឧត្តម មាស សុភា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៥- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ | |
| ៦- ឯកឧត្តម ញ៉ឹម វណ្ណដា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៧- ឯកឧត្តម ស៊ុន ចាន់ថុល | |
| ៨- ឯកឧត្តម ឱម យ៉ិនទៀង | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ៩- ឯកឧត្តម ធៀង មុំលី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១០- ឯកឧត្តម វ៉ា គឹមហុង | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១១- ឯកឧត្តម យឹម ណុលឡា | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១២- ឯកឧត្តម ហ៊ឹម ឆែម | |
| ១៣- ឯកឧត្តម ជិន ប៊ុនស៊ាន | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៤- ឯកឧត្តម ហូ សិទ្ធី | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៥- ឯកឧត្តម យុន ហាំង | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៦- ឯកឧត្តម លី ធុជ | (ទទួលបន្ទុកបេសកកម្មពិសេស) |
| ១៧- ឯកឧត្តម អូស្មាន ហាស្សាន់ | (ទទួលបន្ទុកបេសកកម្មពិសេស) ។ |

**IV-រដ្ឋមន្ត្រី**

| | |
|---|---|
| ១- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី |
| ២- សម្ដេចក្រឡាហោម ស ខេង | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| ៣- សម្ដេចពិជ័យសេនា ទៀ បាញ់ | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| ៤- ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៥- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៦- ឯកឧត្តម វេង សាខុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៧- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ |
| ៨- ឯកឧត្តម ប៉ាន សូរស័ក្ដិ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៩- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

២

| | |
|---|---|
| ១០- ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល |
| ១១- ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ |
| ១២- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ១៣- ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១៤- ឯកឧត្តម ជា សុផារ៉ា | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១៥- ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន |
| ១៦- ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម |
| ១៧- ឯកឧត្តម ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រីក្រសួងព័ត៌មាន |
| ១៨- ឯកឧត្តម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ១៩- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច |
| ២០- ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២១- ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ២២- ឯកឧត្តម ស៊ុន ចាន់ថុល | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២៣- លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ២៤- ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ |
| ២៥- ឯកឧត្តម ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា |
| ២៦- លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ២៧- ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| ២៨- ឯកឧត្តម ពេជ្រ ប៊ុនធិន | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
| ២៩- ឯកឧត្តម ម៉ៅ ហាវណ្ណាល់ | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។ |

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

បរ.ល.១៨០៩.៩៤០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

៣

# ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យត្រាស់ បង្គាប់តែងតាំង និងផ្តល់ឋានៈជូនសមាសភាព ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ចំនួន៣០រូប

(ភ្នំពេញ)៖ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រនៃកម្ពុជា បានចេញព្រះរាជក្រឹត្យត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈជូនសមាសភាព ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ចំនួន៣០រូប ដែលមានឋានៈស្មើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។

មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងឱ្យដឹងថា ការត្រាស់បង្គាប់តែងតាំងនេះនឹងមានបន្ថែមទៀត នៅពេលសាម៉ីគណបក្សស្នើមកកាន់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។

សូមបញ្ជាក់ថា ប្រមុខនៃរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន បានសម្រេចបង្កើត នៅចំពោះមុខប្រធានគណបក្សនយោបាយទាំង១៦ កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ដើម្បីផ្តល់ឱកាសដល់គណបក្សនយោបាយក្រៅរដ្ឋសភាទាំងនោះ ចូលរួមបម្រើជាតិ។

ខាងក្រោមនេះជាព្រះរាជក្រឹត្យត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈជូនសមាសភាព ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់៖

**ព្រះរាជក្រឹត្យ**

នស/រកត/០៩១៨/៩៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** ៖ តែងតាំងនិងផ្តល់ឋានៈជូនសមាសភាពឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ចំនួន ៣០រូបដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម **ឯក សំអុល** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ២- ឯកឧត្តម **ញឹក ប៊ុនឆៃ** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៣- ឯកឧត្តម **ខួន សុដារី** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៤- ឯកឧត្តម **សេង សុខេង** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៥- ឯកឧត្តម **សុខសុវណ្ណ ចន្ទ្រាសាអ៊ុំ** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៦- ឯកឧត្តម **ម៉ម សុណណ្ឌ** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៧- លោកជំទាវ **សុខខៃ សុវណ្ណ បញ្ញាសីលា** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៨- ឯកឧត្តម **ស៊ិន សុភាព** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ៩- ព្រះអង្គម្ចាស់ **នរោត្តម ចក្រាវុធ** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១០- ឯកឧត្តម **ហួត រាជចំរើន** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១១- ឯកឧត្តម **ពេជ្រ ស្រស់** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១២.លោកជំទាវ **ពោធិគី សាមគ្គី** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១៣- ឯកឧត្តម **អង់ មុលីកា** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១៤- ឯកឧត្តម **ស្រួយ ខេត** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១៥- ឯកឧត្តម **កែម រិទ្ធិសិត** | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ១៦- ឯកឧត្តម **និត គឹមហាន** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ១៧- ឯកឧត្តម **អ៊ី សុមន្ធា** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ១៨- ឯកឧត្តម **អាន់ ធិត** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ១៩- ឯកឧត្តម **ឥន្ទ សាម៉ន** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២០- ឯកឧត្តម **សុខ លឹម** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២១- លោកជំទាវ **ហួន ផាន់ណារី** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២២- ឯកឧត្តម **ចន្ទ តាត** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៣- ឯកឧត្តម **ហែម ប្រសើរ** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៤- ឯកឧត្តម **ពេជ្រ សុជាថ្លា** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៥- ឯកឧត្តម **លឹម សំណាង** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៦- ឯកឧត្តម **ហួត ធារិទ្ធ** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៧- ឯកឧត្តម **តាន់ ច័ន្ទផល** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៨- ឯកឧត្តម **អ៊ី មុយលី** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២៩- ឯកឧត្តម **ឡាង ស៊ីន** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣០- ឯកឧត្តម **តុជ លី** | មានឋានៈស្មើ រដ្ឋមន្ត្រី។ |

**មាត្រា២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។






# វេជ្ជបណ្ឌិត សុខារិទ្ធិ មុី

# DR. SOKHARITH MEY, MD



## ចាប់ផ្តើមទទួលអ្នកជំងឺថ្មី
## ទាំងពីរការិយាល័យឡូវែល & លីន

**Now Accepting New Patients at both Offices**

**Family Medicine & Behavioral Health**

**Please Call Us To Enroll:**

**Lowell - (978) 455-7992**

**Lynn - (781) 780-7755**

ផ្នែកជំងឺទូទៅ និងជំងឺផ្លូវចិត្ត

មណ្ឌលពិនិត្យសុខភាពឡូវែល
**Lowell Primary Care Center**
1075 Westford St. Unit 204
Lowell, MA 01851

មណ្ឌលពិនិត្យសុខភាពលីន
**Lynn Primary Care Center**
280 Union St. Unit 402
Lynn, MA 01901

បុគ្គលិកនិយាយភាសាខ្មែរ/ Staff speak Khmer
We accept MassHealth, Medicare and other health insurances

# លទ្ធផលនៃការបោះឆ្នោតតំបន់ ទី៤កញ្ញា ២០១៨

ដោយ ពិន សំខុន

១-បោះឆ្នោត"State rep."នៅសង្កាត់លេខ ១៨ឡូវែលៈ

យើងផ្តោតអារម្មណ៍លើសង្កាត់១នេះ ពីព្រោះជាសង្កាត់ដែលមានខ្មែរយើងរស់នៅច្រើនជាងគេបង្អស់ នាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកនេះ ។ លោក រ៉ាឌី ម៉ម តំណាងរដ្ឋចេញបានឈ្នះឆ្នោតជាថ្មីម្តងទៀត សម្រាប់អាណត្តិ២០១៩-២០ តាមលទ្ធផលដូចនេះ

-អ្នកចេញមកបោះឆ្នោតមាន៥២% ត្រូវនឹងចំនួន៣៩៦៤ ក្នុងចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ចំនួន ៧៦២០

-រ៉ាឌី ម៉ម Rady Mom បានឆ្នោត ១២៧៤

-រិទ្ធី អ៊ុង Rithy Uong បានសម្លេង ១០៥០

-ជីម ឡេរី Jim Leary បានសម្លេង ១០៣០

-សែម មាស Sam Meas បានសម្លេង ៣០៣

វិភាគៈ ការឈ្នះរបស់ រ៉ាឌី ម៉ម អាចបកស្រាយយ៉ាងនេះថា ជាឆ្នោតរបស់ពួកសាសន៍ស្បែកស គាំទ្រយ៉ាងពេញទំហ៊ឹងដោយវរជន"បេកុនហ៊ីល" គឺក្រុមតំណាងរដ្ឋដែលនៅសភា"បូស្តុន"សព្វថ្ងៃ ហើយដែលសម្លេងឆ្នោតទាំងនោះ បានត្រូវចែកគ្នាជាមួយសម្លេងរបស់ ជីម ឡេរី, ក្រុមក្រោយនេះអាចនឹងមិនបានពេញចិត្តនឹងនយោបាយ រ៉ាឌី ម៉ម ទេ, ជីម មិនបានធ្វើការឃោសនាធំដុំអ្វីទេ ក៏គង់បានសម្លេងគួរឱ្យកត់សំគាល់ដែរ ។

រីឯសម្លេងឆ្នោត រីទ្ធី អ៊ុង ភាគច្រើនជាសម្លេងខ្មែរ តែមិនមែនជាឆ្នោតប្រឆាំងនឹង រ៉ាឌី ម៉ម ទេ គឺជាឆ្នោតប្រឆាំងគ្នានឹងសម្លេងឆ្នោត សែម មាស ទៅវិញ ពីព្រោះបើគ្មាន សែម មាស ក៏ដោយ ក៏ឆ្នោតនោះមិនត្រឡប់ទៅ រីទ្ធី អ៊ុង នោះទេ ហេតុអ្វី? ពីព្រោះក្រុមនោះ ជាក្រុមតឹងតែងនិយមប្រឆាំងនឹងនយោបាយភ្នំពេញ, គេនិយាយថា"ពួកគេធ្លាប់គាំទ្រ រីទ្ធី អ៊ុង ដែរតែ រីទ្ធី បានក្បត់នឹងគណបក្សសង្គ្រោះជាតិផ្តាច់ខ្លួនទៅចុះចូលមួយអ្នកនយោបាយបក្សមិនច្បាស់លាស់ សម រង្ស៊ី ហើយចង់មកឡូកឡំក្នុងនយោបាយតំបន់ឡូវែលថែមទៀត មិនអាចដំណាងពួកគេបានទេ" ។

ជាមួយនឹងសម្លេងឆ្នោតរបៀបនេះ សហគមន៍ខ្មែរឡូវែលកំពុងទទួលរងនូវការទិទាន ថាបែកបាក់គ្នាជាបន្តរទៅទៀត មិនអាចទាញយកប្រយោជន៏ពីជ័យជំនះពីដៃ រ៉ាឌី ម៉ម បានទេ, រីឯសម្លេងឆ្នោត រីទ្ធី អ៊ុង ដែលទទួលបានច្រើនលំដាប់លេខ២នោះ ប្រសិនជាបានឈ្នះទៅវិញ ក៏មិនច្បាស់ជាអាចសង្ឃឹមថា "បំរើឡូវែល"បានប្រពៃដែរ ពីព្រោះជាសម្លេងឆ្នោត"មិត្រភក្រ្តនិយម- សម រង្ស៊ី-អេងឆៃអៀង" មិនអាចថាជាស្មារតីឆ្នោត"សហគមន៏ឡូវែលនិយម-ឧត្តមគតិនិយម"ទេ ។ គេមិនមានសញ្ញាថា ក្រុមជនជាតិភាគតិច ពុះកញ្ជ្រោលចេញមកបោះឆ្នោតកាពារបេក្ខជនដែលខ្លួនពេញចិត្តនោះទេ។








លោក រ៉ាឌី ម៉ម

លោក អែដ ខេណឺឌី

( ទាំងពីរនាក់មិនទាន់សម្រេចថា អ្នកណាឈ្នះនៅឡើយទេ

២-លទ្ធផលនៃការបោះឆ្នោត State Senator :

ប្រជាពលរដ្ឋបានចុះឈ្មោះ២២០០១នាក់ ហើយបានចេញទៅបោះឆ្នោតសម្តែងឆន្ទៈ ១១៣៥០នាក់ ត្រូវនឹង ៥១,៦% ។ ការបោះឆ្នោតនេះគឺដើម្បីដណ្តើមយកដំណែងកាន់ដោយលោកស្រី អាលីន ដាណាហ៊ូ ដែលបានលាលែងដំណែងនោះដើម្បីទៅចាប់យកដំណែងជាចាងហ្វាងសាលាក្រុង

តទៅទំព័រទី ១៤



# ការិយាល័យ មេធាវី ចំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

---

All Care Resources

កម្មវិធីថៃទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថៃទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ។

លក្ខខណ្ឌនៃការដាក់ពាក្យក្នុងកម្មវិធីនេះ :

-អ្នកដែលមានជំងឺត្រូវមានអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថៃរក្សានិងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល។

-អ្នកថៃទាំត្រូវមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺតែអ្នកមើលថៃនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ។

-អ្នកថៃទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថៃទាំត្រូវតែមានលទ្ធភាពមើលថៃអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) ដែលស្ទាត់ជំនាញភាសាខ្មែរ តាមរយៈលេខទូរស័ព្ទ ៧៨១-២៤៤-១១១៥ ។

---

COMMUNITY TEAMWORK

# ផ្សារផលិតផលកសិកម្មរបស់កសិករនៅឡូវែល

ថ្ងៃសុក្រ ទី 6 ខែកក្កដា – ថ្ងៃទី 26 ខែតុលា, ម៉ោង 12 pm ដល់ម៉ោង 5 pm
នៅសួន លូស៊ី ឡាខំ ផាក, ផ្លូវ ២៤៨ ម៉ែរីមាក ស្ត្រីត

circlehealth — Aramark Building Community — fallonhealth



បន្លែស្រស់ៗ, អាហារបំប៉នរាងកាយ, ចំណីអាហារ, ផលិតផលដែលធ្វើដោយដៃយ៉ាងពិសេស និងមានអ្វីៗជាច្រើនប្រភេទផ្សេងទៀត

**សប្បាយជាមួយក្រុមគ្រួសារ!**

ការដាក់តាំងបង្ហាញផលិតផលម្ហូបអាហារ, ជន្ត្រី, ល្បែងកំសាន្ត & ការចាប់រង្វាន់!
ទទួលយកអ្នកដែលមាន WIC , ប័ណ្ណចាស់ជរា, ប័ណ្ណSNAP/EBT និងក្រេឌីតកាត

ចំណាយទិញផ្លែឈើ និងបន្លែស្រស់ៗពីកសិដ្ឋាននៅទីផ្សារផលិតផលកសិកម្មរបស់កសិករដោយប្រើប្រាស់ប័ណ្ណ SNAP របស់លោកអ្នក ហើយចំនួននៃការចំណាយទិញរបស់លោកអ្នក នឹងត្រូវបានបូកបញ្ចូលបន្ថែមទៅក្នុងប័ណ្ណ EBT របស់អ្នក!

ត្រូវការជំនួយក្នុងការធ្វើដំណើរមកកាន់កន្លែងលក់? មិនមានបញ្ហា!

| | |
|---|---|
| ទីតាំងមជ្ឈមណ្ឌល ស៊ីនឌៀ ស៊ិនជ័រ -- ផ្លូវ 276 Broadway St. | មានឡានមកយកនៅម៉ោង 11:45 |
| ទីតាំងអគ្គាធរលំនៅដ្ឋាន (Housing Authourity)-- ផ្លូវ 21 Salem St. | មានឡានមកយកនៅម៉ោង 12:45 |
| ទីតាំងអគ្គាធរលំនៅដ្ឋាន-- ផ្លូវ 580 Salem St. | មានឡានមកយកនៅម៉ោង 12:45 |

ធ្វើដំណើរត្រឡប់មកវិញពីផ្សារមកកាន់ទីតាំងដែលឡានមកយកនៅម៉ោង 1:40 pm -- មានសេវាដឹកជញ្ជូនគ្រប់កន្លែងលក់ទាំងអស់

រកព័ត៌មានអ្វីៗដែលថ្មីៗរបស់ផ្សារផលិតផលកសិកម្ម សូមចុះឈ្មោះដោយ Sign up ដើម្បីទទួលព្រឹត្តិប័ត្រព័ត៌មានរបស់យើង

សូមចូលទៅកាន់វិបសាយរបស់យើង៖ www.commteam.org/farmers-market

#lowellfarmersmarket #liveatthemarket #LowellMrkt

---

MASSACHUSETTS
**HEALTH CONNECTOR**
*for Business*

ការផ្តល់ការធានារ៉ាប់រងសុខភាពមិនមែនជាការចំណាយទេ,
វាជាការវិនិយោគមួយនៅក្នុងក្រុមរបស់ខ្ញុំ។

"ហ៊ែលកូណិកទ័រ"សម្រាប់ពាណិជ្ជកម្ម
ផ្តល់នូវការគ្របដណ្តប់បុគ្គលិករបស់អ្នកសមនឹងទទួលបាន,
ក្នុងតម្លៃដែលអ្នកអាចទិញបាន។

- សងថ្លៃបំប៉នសុខភាពល្អ
- ឥណ្ឌទានពន្ធ
- មិនគិតថ្លៃបន្ថែម



សូមចូលមើលគេហទំព័ររបស់យើងសម្រាប់ជំនួយបន្ថែម: **MAhealthconnector.org/middlesex**

# Making Connections: The 40th Anniversary of Lowell National Historical Park Exhibit and Opening Reception at The Brush Art Gallery

LOWELL, MA. – As a longtime partner, the Brush Art Gallery and Studios is proud to host “Making Connections: The 40th Anniversary of Lowell National Historical Park.” Forty years ago, Congress established a National Historical Park in Lowell, Massachusetts. This exhibition, co-created by the Brush and the park, features objects from Lowell National Historical Park’s collection, and celebrates the park’s anniversary. These objects enable us to reflect on the past, present, and future of Lowell and the park. The exhibition will be on view beginning Saturday, September 22, 2018 and continues through Saturday, November 3, with a public reception on Saturday, September, 29 from 2 to 4PM

Themed sections of the exhibit include Before the Park, a selection of pre-park objects; Making the Park, Lowell’s physical restoration; Telling the Story, education and interpretation; Living Lowell, Lowell Folk Festival and other cultural features; and The Future Park, visitor interactives and future plans and proposals. The exhibition features historical items from the park museum collection, interactive elements, and commissioned renditions of a futuristic Lowell National Historical Park. Lowell-based freelance illustrator Mark Fisher and designer/illustrator Will Winslow, are the featured creatives for this timely topic as the city of Lowell undergoes new infrastructure and cultural upgrades.



The Brush Art Gallery and Studios is located in the Lowell National Historical Park across the courtyard from the Visitor Center. This dynamic and captivating place was originally founded by the Lowell Historic Preservation Commission, U.S. Department of the Interior. The Brush presents museum quality exhibitions, educational programs, and has collaborated with many other nonprofit groups. Artists occupy studio spaces to interact with and educate the public on a weekly basis. Studio artists produce paintings, illustration, photography, jewelry, sculpture, ceramics, quilts, and handwoven items. Associate artists display work in the common area.

The Brush Art Gallery and Studios is a nonprofit, 501(c)(3) organization. The Brush is supported by the Lowell National Historical Park and Eastern National. For more information on The Brush Art Gallery and Studios, please contact James Dyment at 978.459-7819 or www.thebrush.org.

To learn more about this and other Lowell National Historical Park and partner offerings including the Junior Ranger program, Boott Cotton Mills Museum, Mill Girls and Immigrants Exhibit, ranger-led tours, and upcoming special events stop by the Visitor Center at 246 Market Street, or contact Lowell National Historical Park at (978) 970-5000, or visit www.nps.gov/lowe.






# AG'S OFFICE ANNOUNCES NEW GRANT PROGRAM TO HELP CONSUMERS PAY THEIR HEATING BILLS

$3 Million Grant Program to Provide Additional Funding to State Agencies, Municipalities, And Nonprofits That Assist Households in Paying Monthly Gas Bills

BOSTON – Attorney General Maura Healey today announced a new $3 million grant program to help Massachusetts consumers pay or lower their monthly natural gas heating bills.

"Every year, tens of thousands of Massachusetts families struggle to pay their heating bills," said AG Healey. "My goal with this new program is to make sure our residents have the financial assistance they need to stay warm during the cold winter months."

The Natural Gas Fuel Assistance Grant Program will provide additional funding to programs that assist Massachusetts households in paying for their natural gas service. The grant program is open to programs run through state agencies, municipalities, charitable



organizations, and nonprofit organizations. Eligible programs may include those that are providing direct assistance to consumers by subsidizing their natural gas heating bills or are providing indirect assistance by helping residents implement energy-efficiency measures designed to lower their natural gas heating bills.

"Utility companies terminate gas service to large numbers of low income households each year because those customers cannot afford to pay their bills," said Charlie Harak, a managing attorney at the National Consumer Law Center. "The Attorney General's program will help thousands of households to stay current on their bills and avoid termination."

The AG's Office is especially interested in proposals for programs that will provide funding to families who otherwise would not be receiving fuel assistance, or who are not receiving sufficient help in paying their monthly heating bills.

The grant program will utilize funds the AG's Office secured through a settlement with National Grid for improperly charging its customers reconnection service fees.

As the ratepayer advocate for Massachusetts, AG Healey works to ensure that consumers do not pay more than they should for their natural gas. In July 2017, AG Healey joined a coalition of 35 attorneys general and state consumer advocate agencies in urging Congress to preserve and expand funding for the Low-Income Home Energy Assistance Program (LIHEAP) and the Weatherization Assistance Program (WAP), federally funded low-income energy assistance programs.

The two-year grant program will start on Nov. 1, 2018 and will end on Oct. 31, 2020. Interested applicants can visit the AG's website, www.mass.gov/ago/grants for more information and for application instructions. Questions about the grant program can be submitted by email to AGOGrants@state.ma.us by 5 p.m. on Sept. 12, 2018. Applications must be received by 5 p.m. on Sept. 21, 2018.

KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយក សុបិន្ត ពិន Soben Pin, *Co-Founder/Publisher*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Co-founder/Editor*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Staff Writer/Translator**
Sokharath Koy
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA

LOWELL COMMUNITY HEALTH CENTER

Lowell CHC Metta Health Center is now located on the 3rd floor of 161 Jackson Street



978.937.9700 | www.lchealth.org

# សម រង្ស៊ី កូរទឹកអម្រឹតរកជីវិតអមតៈ

ទស្សនៈនយោបាយដោយ ពិន សំខុន

ក្នុងជីវិតនយោបាយថ្មីៗរបស់លោក សម រង្ស៊ី ក្នុងឋានៈជាអតីតនឹងបច្ចុប្បន្នមេបក្សប្រឆាំងមិនបានធ្វើឱ្យគេយល់ថា“លោកកំពុងតែប្រយុទ្ធតទល់ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រីផ្តាច់ការនិយម ហ៊ុន សែន នោះទេ, ផ្ទុយទៅវិញ លោកបែរជាធ្វើឱ្យគេឯងឃើញថា““លោកកំពុងស្វែងរកជីវិតអមតៈមួយ ដោយខិតខំប្រគួតតែជាមួយគ្នាឯងនៅក្នុងបក្សប្រឆាំងដូចគ្នាឱ្យប្រយោជន៍ទៅខ្មាំងរបស់ខ្លួន”ទៅវិញ ដែលរឿងនេះ ស្របនឹងរឿងព្រេងបូរាណខ្មែរ ដែលមានម្ខាងជាក្រុម“យក្ខ” នឹងម្ខាងទៀតជាក្រុម“ទេវតា” ទាញព្រ័ត“កូរសមុទ្រទឹកដោះ”ដណ្តើមយក“ជីវិតអមតៈ” ដើម្បីយកឈ្នះសម្រាប់តែខ្លួនឯងតែម្នាក់ ។ហេតុអ្វីក៏ទៅជាដូច្នេះទៅវិញ?

ថ្មីៗនេះសោះ ដែល សម រង្ស៊ី បានប្តូរបង្ហាញមុខនយោបាយថ្មីរបស់ខ្លួន គឺនៅពេលដែល ហ៊ុន សែន ផ្តើមនយោបាយវាយផ្តាច់ព្រ័តមុនពេលបោះឆ្នោតសារជាថ្មី នាពាក់កណ្តាលឆ្នាំ២០១៧ គឺទៅរំលាយគណបក្សសង្គ្រោះជាតិ -ចាប់លោក កឹម សុខា ជាប្រធានដាក់គុក-ទុក សម រង្ស៊ី ឱ្យនៅឆ្ងាយពីទីលានប្រយុទ្ធនយោបាយឯបរទេស -រំលាយសិទ្ធនយោបាយរបស់សមាជិកជាន់ខ្ពស់នៃបក្សប្រឆាំងចំនួន១១៨រូប ពេលនោះពលរដ្ឋខ្មែរ នៅក្រៅប្រទេសទាំងអស់ប្រកបដោយការគាំទ្រពីប្រទេស



សេរីទាំងអស់បានក្រោកឈរព្រមគ្នាប្រឆាំងនឹងរបបផ្តាច់ការនិយម ហ៊ុន សែន ...ស្រាប់តែបាត់ សម រង្ស៊ី មិនបាននៅជាមួយគេឯង ក្នុងបាតុកម្មរួមគ្នាទេ ដែលពេលនោះ ជាឱកាសដ៏ប្រពៃបំផុតសម្រាប់លោក“ត្រឡប់”មកចូលមកសង្គ្រោះជាតិវិញ ក្នុងឋានៈជាមេដឹងនាំជាន់ខ្ពស់បានយ៉ាងងាយស្រួល...ប៉ុន្តែលោកបានយកពេលដ៏មានតម្លៃនោះទៅបង្កើតសមាគម...។ មួយសម្រាប់លោកធ្វើជាប្រធាន -បន្ទាប់មកទៅបង្កើតចលនាសង្គ្រោះជាតិមួយ ដើម្បីលោកធ្វើជាប្រធាន-រួចទៅបង្កើតគណបក្សសង្គ្រោះជាតិអាមេរិកា ដើម្បីលោកធ្វើជាប្រធាន...។ការហក់លោតច្រើនវគ្គច្រើនសារនោះរបស់លោក សម រង្ស៊ី បានបំបែកចលនាដ៏ធំមួយដែលកំពុងប្រឆាំងនឹងលោក ហ៊ុន សែន ឱ្យកាន់តែតូចទៅៗដោយលោកខិតខំជាមួយមន្ត្រីជាន់ខ្ពស់សង្គ្រោះជាតិជា“កូតា”របស់លោកទៅបំបែក“គណបក្ស”សង្គ្រោះជាតិឱ្យទៅជាក្រុម សម រង្ស៊ី -ក្រុម កឹម សុខា មិនឈប់ឈរ រហូតមកដល់ពេលនេះ, ការក៏កូរសមុទ្រទឹកដោះ ដើម្បីជីវិតអមតៈរបស់លោកបានសម្រេចជោគជ័យគួរឱ្យកោតសសើរ ដែលមនុស្សជាច្រើនហៅក្រុមម្ខាងនៃគណបក្សសង្គ្រោះជាតិថា“ជាក្រុមសង្គ្រោះចោរ” រីឯក្រុមម្ខាងទៀតហៅថា ជា“ក្រុមមាន់ឥតក្បាល” ពីព្រោះលោកប្រធានបានយកមេៗរបស់ ពួកគេអស់ទៅធ្វើជាសាវ័ករបស់លោកដោយគេមិនដឹងថាលោកបាន“សន្យាអ្វីខ្លះ”ដល់អ្នកទាំងនោះ បានជាអ្នកទាំងនោះសុខចិត្ត“ក្បត់”បោលចោលកូនចៅដោយគ្មានស្តាយស្រណោះអ្វីបន្តិចសោះអីចឹងទៅកើត? ។

ឆ្ងាយជាងទទួលបានឈ្មោះដ៏សមរម្យនេះហើយមិនទាន់អស់ចិត្តទៀត គាប់ជួនជាមានសមាជិកសង្គ្រោះជាតិជាមន្ត្រីស្រ្តីដ៏ក្មេងម្នាក់ឈ្មោះ កឹម មនោវិទ្យា ជាកូនស្រី កឹម សុខា ហ៊ានទៅធ្វើកិច្ចការបរទេសនៅអូស្ត្រាលី បានជោគជ័យដ៏ធំធេងមួយជូនប្រទេសជាតិជូនប្រជាពលរដ្ឋខ្មែរ... ក៏មិនអត់ឱនឱ្យដែរ! លោក សម រង្ស៊ី បានទាមទារក្នុងលិខិតដ៏ខ្លីប្រកបដោយពាក្យអសុរសថា “ជាស្នាដៃរបស់លោក”ថា“គ្មាននរណាប្រសើរជាងលោកទេ” នេះមិនសមជាពាក្យរបស់ សម រង្ស៊ី ដែលធ្លាប់ជាប្រធានបក្សប្រឆាំងដ៏ក្លាហាន ដ៏គួរឱ្យគោរពពីពេលមុនមកនោះទេ! នៅមានទៀត លោក កឹម សុខា ជាដៃគូរប្រយុទ្ធ បាន “បូជាឱកាសក្នុងគុក” របស់លោក ដើម្បីឱ្យលោកអាចតស៊ូខាងក្រៅ ដោយមានបុព្វហេតុជាក់ស្តែងបាន តែលោកបែរជានិយាយថា“មនុស្សនៅក្នុងគុកមិនអាចនិយាយអ្វីបានទេ”!! ហេតុអ្វីក៏ម៉ង់ដែឡា ឬអូនសាន់ស៊ូជី ដែលបានក្លាយជា“មនុស្សគំរូ”របស់លោក ដោយតស៊ូពីក្នុងគុកមកបានបែរជា កឹម សុខា ដែលលោកហៅថា ជាដៃគូរប្រយុទ្ធរបស់លោក បែរទៅជា “គម្រក់” ទៅវិញ នេះជាពាក្យកុហកដែលលោកភ្លេចខ្លួននិយាយចេញមកនៅពេលលោកអាយុច្រើនពេកទៅហើយ ។ លោក ហុង លឹម ជាមន្ត្រីនយោបាយអូស្ត្រាលីទំនងជានិយាយមិនខុសទេ នៅពេលដែលថា“លោកអាយុច្រើនពេកហើយនោះ គួរតែទុកឱកាសឱ្យក្មេងៗគេប្រឡូកជំនួសលោកម្តងវិញ...” តែនោះ ក៏នៅតែមិនមែនជាច្បាប់របស់សង្គ្រោះជាតិទេ។

តទៅទំព័រទី ១៣









## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបានបង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែលឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត ។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe" ។

# សាលាកងកុមារយោធិន្ទការមកដល់នៃសិស្សថ្មី (ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ ការមកដល់នៃសិស្សថ្មី (ត)**

តាមពិតទៅប្រាក់បៀវត្សរ៍១២៩រៀល មិនច្រើនទេ តែបើប្រៀបធៀបទៅនឹងកូនទាហ៊ានដែលមានបន្ទុកបើកប្រាក់បានតែ១២០០រៀលក្នុងមួយខែ ឃើញថា ច្រើនគួរសមដែរ -តែបើ-ប្រៀបធៀបទៅនឹងយុវជនឯទៀត ជាស៊ីវិលហើយគ្មានប្រាក់ចំណូលសោះទៅវិញនោះ ឃើញថាប្រាក់ខែកុមារយោធិន្ទទទួលបានច្រើនគួរសមដែរ ។

កុមារយោធិន្ទ មិនចេះសន្សំលុយទេ ពីព្រោះមិនដែលឮថា អ្នកណាមានសល់លុយអ្វីបាននោះទេ តែពួកគេនៅអាចនៅសល់លុយច្រើនក្រៃលដែរនៅក្នុងគណនីយដែលលោក"អូដេ"សន្សំទុកឱ្យមានចំនួន១២៩រៀលដូចគ្នាក្នុង១ខែ ដោយសារសិស្សម្នាក់ៗរស់នៅច្រើនឆ្នាំក្នុងសាលារបស់ខ្លួនប្រាក់នោះក៏កើនចំនួនក្លាយទៅជាក្រៃល រហូតដល់បានច្រើនពាន់រៀលនៅពេលខ្លួនត្រូវចាកចេញពីសាលរៀននៅចុងបញ្ចប់ -តើពួកគេត្រូវទៅណាទៀត?

នាខែកញ្ញា ឬក៏ខែតុលាមកដល់នៅពេលដែលមានសិស្សថ្មីហើយក្មេងៗមកដល់ក៏មានកុមារយោធិន្ទមួយចំនួនចូលដល់គ្រប់អាយុ១៨ឆ្នាំ អ្នកទាំងនោះមិនអាចនៅរៀននៅសាលាកុមារយោធិន្ទបានតទៅទៀតទេ សិស្សចាស់ទាំងនោះត្រូវទៅបន្តការសិក្សារបស់ខ្លួនជាទាហ៊ានវិជ្ជាជីវៈ ដោយមិនចាំបាច់ប្រឡង ឬក៏ឆ្លងកាត់ការជ្រើសរើសណាទៀតទេ គឺកងទ័ពយកឱ្យចូលជាស្ម័យប្រវត្តិក្នុងកំរិតដែលកុមារយោធិន្ទម្នាក់ៗបានរៀនសូត្រ ។ ជាទូទៅសិស្សទាំងអស់ដែលមកដល់អាយុ១៨ឆ្នាំ



ហើយឋិតនៅថ្នាក់កំរិតវិទ្យាល័យ ចន្លោះថ្នាក់ទី៥នឹងថ្នាក់ទី៣ លោកមេបញ្ជាការត្រូវបញ្ជូនអ្នកទាំងនោះទៅកាន់ខេត្តពោធិ៍សាត់ ជាទីដែលមានការអប់រំវិជ្ជាជីវថ្នាក់ "ភ១ ឬក៏ ភ២" គឺបើរៀននៅ ភ១ យោធានោះនឹងបានបញ្ចប់ដោយបានពាក់សក្តិ"Caporal" បើគេហាត់រៀនហើយបញ្ចប់នៅកំរិត ភ២ ជាបន្តរទៅទៀតនោះ យោធានោះនឹងបានពាក់សក្តិ"Sergent" បើយោធាណាទៅរៀនបានដល់កំរិត"ភ៣"វិញនោះ គេនឹងចេញមកបានពាក់សក្តិ" Sergent Chef"តែម្តង តែមានតិចណាស់ដែលឆ្លងទៅដល់កំរិតនោះ ដូច្នេះយោធាម្នាក់ៗត្រូវចេញទៅបំរើក្នុងកងទ័ពក្នុងចំនួនច្រើនឆ្នាំ១៤-៥ឆ្នាំបក្នុងឋានៈជា Sergent សិន មុននឹងអាចចូលរៀន ភ៣ បាន ។ម្ល៉ោះហើយសិស្សកុមារយោធិន្ទច្រើនតែបានទៅបន្តសិក្សានៅត្រឹម ភ១ -ភ២ តែប៉ុណ្ណោះ រួច១ឆ្នាំឬ២ឆ្នាំក្រោយមក គេបញ្ជូនកម្មសិក្សាដែលរៀនចប់ ទៅកាន់កងឯកភាព



ម៉ាប៉ុន កុមារយោធិនកាលពី៥០ឆ្នាំមុន

តែម្តង ។

នៅមានសិស្សមួយចំនួនទៀតដែលបានដល់ថ្នាក់ប្រឡងជាប់"Diplome"ជាប់ឡើងទៅថ្នាក់ទី២-ទី១-ថ្នាក់បញ្ចប់,សិស្សទាំងនោះត្រូវបញ្ជូនទៅឱ្យ"ប្រឡង"ចូលសាលានាយទាហ៊ាន"EOA Eleve des officiers actifs" ដើម្បីឱ្យបានពាក់ពី"Aspirant" - សក្តិ១ឡើងទៅ -គឺគេត្រូវប្រឡងប្រជែងចូលសាលាដែលកុមារយោធិន្ទម្នាក់ៗចង់ឱ្យបានទៅទីនោះ តែតិចណាស់បានរៀនទៅដល់នោះ គឺគេត្រូវទៅហាត់ហ្វឹកហ្វឺនជានាយទាហ៊ានចំនួន៣ឆ្នាំ ដោយនាយទាហ៊ានមកជាជំនួយយោធាបារាំងមកឱ្យកម្ពុជាសិស្សពូកែក៏អាចបញ្ជូនជូនទៅរៀនឯស្រុកបារាំងថែមទៀត ។ សិស្សជំពូកក្រោយនេះ តែងលាគ្នាប្រកបដោយភាពរីករាយជូនពរគ្នា ពីព្រោះគេដឹងថា មិត្តរបស់គេនឹងទទួលបានឋានន្តរសក្តិប្រសើរជាមិនខាន ។ ចំណែកឯសិស្សដែលត្រូវលាទៅរៀន ភ១-ភ២ វិញ គេមិនសូវជារីករាយប៉ុន្មានទេ ខ្លះក៏ទឹកភ្នែកទឹកសម្បោរ ដោយមិត្ររបស់គេ ត្រូវចេញដំណើរនៅព្រឹកព្រហ៊ាមម៉ោង២ទៀបភ្លឺនាព្រឹកថ្ងៃស្អែកឡើង ដឹកដោយរថយន្ត GMC ចេញដំណើរទាំងក្រុម ដើម្បីបន្តរទៅរៀនយ៉ាងលំបាកថែមទៀត ហើយបានសក្តិក៏មិនសូវខ្ពង់ខ្ពស់ដែរ- នៅពេលតម្រូវឱ្យទៅរៀននៅខែត្រពោធិ៍សាត់ នៅទីនោះជាសាលាដែលសួរអ្នកគ្រប់គ្រងពលទាហ៊ានដោយផ្ទាល់ ដែលជាជន្ទល់ដ៏សំខាន់របស់កងទ័ពនៃប្រទេសកម្ពុជា តាមគំរូរបស់បារាំង ដែលបានបង្សល់ទុកជូនកម្ពុជាសម្រាប់ការពារប្រទេស នៅពេលអាណានិគមបារាំងចាកចេញទៅ ។

ការបែកគ្នានេះបានត្រូវអតីតកុមារយោធិន្ទឆ្នាំ១៩៦២ ម៉ា ប៉ុន អត្តលេខ"៨៤៩-វីសង់ការ៉ងនើហ្វ"និយាយពីការចងចាំរបស់ខ្លួនថាៈ កាលពីនៅកុមាយោធិន្ទ ខ្ញុំច្រើនជាក្មេងខិលខូចជាងគេ ខ្ញុំចាំថា "ពេលមួយនោះ អា " ៨១៩ វិតសង់ឌីនើហ្វ "ឈ្មោះវាអា ឡុង ចាន់ធូ អានោះក៏ខូចណាស់ដែរ ពេលមួយនោះ អានោះវាញស់ខ្ញុំខ្លាំងពេក ខ្ញុំក៏ខឹងហើយក៏ទាញស្បែកជើង"ប្រូដឺកាំង"( ជាស្បែកជើងទាហ៊ានរឹងដូចដុំថ្ម) ដេញវាយវា... កំពុងប្រទាញប្រទង់គ្នា ស្រាប់តែលោក"សែហ្សង់" សែពឈន មកដល់ បានចាប់ខ្លួនយើងទាំង២សួរដេញដោលចម្លើយ ដល់បានដឹងថាយើងឈ្លោះគ្នាមែន ក៏យកទៅដាក់គុកទាំង២នាក់ជាមួយគ្នា -គុកនោះជាបន្ទប់តូចមួយ មាន"បាប្លង់ ពារ-ផលាន" សម្រាប់ដេកគ្មានភួយគ្មានមុងទេ -ខ្ញុំខ្លាចវាវាយខ្ញុំបន្តរទៀត ពីព្រោះវាមានមាឌធំជាងខ្ញុំ ក៏គម្រាមដកជើងគ្រែ"បាផ្លង់"ធ្វើពីឈើ ថា"តែឯងមកវាយអញ៧នឹងដាក់ឯងមួយដំបងហើយ..." យើងក៏មិនហ៊ានចូលជិតគ្នា ហើយដេកក្នុងទីងងឹតនោះទល់ភ្លឺស្រាងៗ ទើបគេដោះលែងឡើងវិញដើម្បីឱ្យយើងអាចទៅរៀនបាន..." ។ ម៉ា ប៉ុន បន្តថា "ចេញពីគុកមកវិញ ស្រាប់តែជួបរៀមច្បង យ៉ុន បាន (ហៅសូឡិចក្បាលស ពីព្រោះមានពងក្តខ្មៅតែក្បាលវាពណ៌ស) គម្រាមថា ឯងនេះត្រូវឈប់ទៅញ៉ែស្រីរបស់អញទៀតឮទេ តែអញដឹងទៀតអញនឹងខោកក្បាលងាប់!" ។

ការលាបែកគ្នាទៅរៀនសាលាថ្មី បន្ទាប់ពីបានរស់នៅជាមួយគ្នាច្រើនឆ្នាំ ក៏ក្លាយជាមិត្តរួមជីវិតជំនួសជីវិតគ្រួសារបង្កើតបានយ៉ាងប្រសើរបានដោយសាររៀនជាមួយគ្នា ហាត់ជាមួយគ្នាទទួលទោសជាមួយគ្នាសមគំនិតក៏ជាមួយគ្នាស៊ីបាយក៏ជាមួយគ្នា តែយោធាមានវិធីសម្រាប់គ្រប់គ្រងកុមារយោធា៣០០នាក់ យ៉ាងងាយស្រួលបានដោយ"វិន័យកងទ័ព" ចុងបញ្ចប់ជីវិតនោះ ពង្រឹងចំណេះ"កិច្ចកាងាររួមគ្នារហូតដល់ហ៊ានពលីជីវិតបូជាជូនជាតិ"ដែលជាសេចក្តីត្រូវការខ្ពស់បំផុត ក្នុងចំណោះសង្គ្រាមរបស់កងទ័ពកាត់ថ្លៃមិនបាន ។

(នៅមានត)

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មានវែហិលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**
- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***
- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ១០

# សម រង្ស៊ី កូរទឹកអម្រឹតរកជីវិតអមតៈ

នៅមានឱកាសសម្រាប់ដោះស្រាយទំនាស់ផ្ទៃក្នុងមួយទៀត ដែលនាំឱ្យមេដឹកនាំនៅក្រៅប្រទេសរបស់គណបក្សសង្គ្រោះជាតិមានកំហុសដ៏ធំធេងមួយ គឺលោក សម រង្ស៊ី មិនបានរំលឹកដល់សមាជិកសកម្មរបស់លោកពីការមិនគោរពលក្ខន្តិកៈរបស់គណបក្សសង្គ្រោះជាតិ ឬក៏គណបក្សនេះគ្មានលក្ខន្តិកផងក៏មិនដឹង!... មានមិត្តខ្ញុំម្នាក់បានសួរខ្ញុំមកថា "តើនៅពេលអវត្តមានរបស់ប្រធានគណបក្សលក្ខន្តិកៈគេនិយាយថា ម៉េច?" គ្មាននរណាដែលលើកពីមាត្រាមួយនេះមកនិយាយសោះ ពួកអនុប្រធានដែលនៅក្រៅស្រុក ក៏មិនបានដឹងគិតតែពីការពារលោក សម រង្ស៊ី ក្រែងមិនបានគេជ្រើសតាំងជាប្រធាន!!! គេនាំគ្នាដោះស្រាយពីបញ្ហា"ក្រៅច្បាប់" ដែលខ្លួនឯងបានចែង "ក្នុងច្បាប់"រួចជាស្រេចមកហើយ... តែបើមាត្រានោះបែរជាគ្មានទៅវិញ គេគួរតែគ្មានសមត្ថភាពអ្វីនឹងតាំងខ្លួនមកដឹកនាំប្រទេសកម្ពុជានោះទេ... ជាងនេះទៅទៀត គឺមិនមានសមត្ថភាពនឹងគ្រោងរំលំ ហ៊ុន សែន បានឡើយ ។

ពលរដ្ឋខ្មែរនៅសល់សំណាងល្អមួយដែរ គឺគុណបុណ្យ"កិច្ចព្រមព្រៀងក្រុងប៉ារីស"នឹង"សហគមន៍អន្តរជាតិ"ដែលតាមដានលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា គេដាក់គំនាបស្របតាមសំណើរកូនស្រីលោក កឹម សុខា ជាអនុប្រធានគណកម្មការកិច្ចការបរទេសអមដំណើរដោយ តំណាងរាស្ត្រ យ៉ែម ប៉ុញ្ញាឫទ្ធ... ហេតុអ្វីក៏អ្នកទាំង២មានប្រជាប្រិយភាពខ្លាំងម្ល៉េះក្នុងពិភពលោកសព្វថ្ងៃនេះ? អ្នកមានទឹកមាត់ប្រៃ ពីព្រោះគេ "ជឿទៅលើការគិតត្រូវ" ស្របតាមបំណងនៃ"ប្រវត្តិតស៊ូរំដោះប្រទេសខ្មែរពីដៃកុម្មុយនិស្ត"នឹងស្របតាមបំណងនៃ"កំណើតគណបក្សសង្គ្រោះជាតិ"។ លោក សម រង្ស៊ី មិនទាន់ខកដំណើរនៅឡើយទេ ការថយចេញពី"បំណងបំបែកបំបាក់"ហើយត្រឡប់មកចូលរួមប្រយុទ្ធក្នុងរង្វង់គណបក្សសង្គ្រោះជាតិវិញ ពីព្រោះនៅខាងក្រៅពីនេះ ពុំមាននរណាជឿ"ចម្រៀងពិរោះស្តាប់"របស់លោកប្រធានទៀតទេ ហើយតែរង់ចាំបន្តិចទៀតទៅនោះ លោកនឹងក្លាយជាមនុស្សគ្រោះថ្នាក់បំផុត សម្រាប់"សេរីភាព"ប្រជាជាតិខ្មែរ បើលោកនឹងក្រុមលោកនៅតែចចេស ។

ការតស៊ូលើកនេះ ជាការតស៊ូដ៏ធំធេង"ពីខាងក្រៅប្រទេស"ដែលកំពុងតែទទួលផលជាវិជ្ជមានអ្នកទោសនយោបាយកំពុងចេញពីគុកខ្មែរព្រោងព្រាតនេះប្រាកដជាមិនមែនរបស់លោកម្នាក់ឯងនោះទេ ដោយសារតែលោកមិនបានធ្វើសកម្មភាពជា"អ្នករួបរួមគណបក្សសង្គ្រោះជាតិ" ។

បារីសថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨










តមកពីទំព័រទី ០២

## បាតុករសង្គ្រោះជាតិនៅ"ត្រូកាដេរ៉ូ"...

ប្រទេសកម្ពុជាថា"កម្ពុជាកំពុងរងគ្រោះពិការឈ្លាន ពានរបស់បរទេសគ្រប់ផ្នែកអស់ទៅហើយមាន ទាំងយួនក៏ចូលពេញស្រុក រីឯចិនក៏មកវាតទីគ្រប់គ្រងទាំងសេដ្ឋកិច្ចនឹងនយោបាយកម្ពុជាពាសពេញអស់ទៅហើយដែរ... ការបោះឆ្នោតដែលកន្លងទៅថ្មីៗនេះ ពោរពេញដោយការលួចបន្លំសន្លឹកឆ្នោត លួចដំណែងតំណាងរាស្ត្រនឹងប្លន់អំណាចសម្រាប់តែគ្រួសារលោក ហ៊ុន សែន នឹងគណបក្សប្រជាជនតែប៉ុណ្ណោះ... ពលរដ្ឋខ្មែរត្រូវភ្ញាក់ឡើងហើយរួមកម្លាំងគ្នាយកប្រជាធិបតេយ្យមកជូនកម្ពុជាវិញ...។

ព្រះតេជគុណ អួង សុខ មកពីសមាគមប្រចាំអឺរ៉ុប គាំទ្រកិច្ចព្រមព្រាង២៣តុលា១៩៩១ នៅខេត្រ"ប្លីរ Blois" យើងមិនទទួលស្គាល់ការបោះឆ្នោតថ្មីៗនេះនៅកម្ពុជាសុំឱ្យអន្តរជាតិដាក់ទណ្ឌកម្មជាទំងន់ដល់មេដឹកនាំខ្មែរបច្ចុប្បន្ននឹងជម្រុញឱ្យមានការដោះលែងលោក កឹម សុខា ជាបន្ទាន់ -យើងទាមទារឱ្យមានតំណាងរាស្ត្រ១១៨រូប មានសិទ្ធពេញលេញជាតំណាងរាស្ត្រខ្មែរឡើងវិញ ឱ្យមេឃុំចៅសង្កាត់ដែលបានជាប់ឆ្នោតត្រឡប់មកធ្វើការបំរើរាស្ត្របានមកវិញ ឱ្យមានការបោះឆ្នោយសារជាថ្មី ដោយមានគណបក្សសង្គ្រោះជាតិចូលរួមប្រកួតទាំងអស់នេះហើយ ដែលធ្វើឱ្យមានលទ្ធិប្រជាធិបតេយ្យត្រឡប់មកកម្ពុជាវិញនោះ...ខ្មែរគ្រប់កន្លែងទាំងខ្មែរកណ្តាលខ្មែរក្រោម ខ្មែរលើ ត្រូវតែប្រមូលកម្លាំងរួមគ្នាធ្វើការដើម្បីមាតុភូមិឡើងវិញ...។



បាតុករបាននាំគ្នាស្រែកអាក្រោសដាក់កំហុសឱ្យ ហ៊ុន សែន ជាអ្នកផ្តាច់ការនិយមជាអ្នកបំផ្លាញប្រជាធិបតេយ្យចូលដៃដោយគណបក្សប្រជាជនជាគណបក្សកុម្មុនិស្ត... ពួកគេស្រែកបំពងសម្លេងទាមទារឱ្យដោះលែង កឹម សុខា ពីពន្ធនាគារដែលគេដាក់ដោយគ្មានទោសគ្មានការចោទប្រកាន់ទាមទារឱ្យបង្កើតលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាឡើងវិញ។

បាតុកម្មបានបញ្ចប់ទៅវិញ នៅម៉ោង៦ល្ងាចនៃថ្ងៃដដែល។

តមកពីទំព័រទី ០៦

## លទ្ធផលនៃការបោះឆ្នោតតំបន់...

ឡូវែល កាលពីដើមឆ្នាំ២០១៨នេះ។លទ្ធផលមានដូចតទៅ :

-អេដ ខេណ្ណឺឌី Edward Kennedy បច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាក្រុងឡូ បានឆ្នោត ២៩៣៨

-រ៉ដនីយ អេលីយ៉ុត Rodney Elliott បច្ចុប្បន្នជាសមាជិកក្រុមប្រឹក្សាក្រុងឡូ បានឆ្នោត ២៨៧៤

-ជន ឌ្រីងវ៉ធ័រ John Drinkwater បានឆ្នោត ២៣៣១

-វីលាម ម៉ាទីន William Martin បានឆ្នោត ១៤៨១

-ទេរី រ៉ាយាន Terry Ryan ជាវិស្វករ បានឆ្នោត ៩៥០

លោក អេដ កេណ្ណឺឌី បានត្រូវប្រកាសថាឈ្នះនៅជុំទី១ ត្រូវទៅជួបប្រកួតជាមួយបេក្ខជនគណបក្សសាធារណរដ្ឋជន ម៉ាកដណល នៅខែវិច្ឆិកាខាងមុខទៀត។

នៅពេលជាប់ឆ្នោតភ្លាម អេដ កេណ្ណឺឌី បានប្រកាសថា"នឹងនៅរក្សាដំណែងសមាជិកក្រុមប្រឹក្សាក្រុងឡូវែល រហូតដល់ចប់អាណត្តិ" ការសន្យានេះបានន័យថា ជាសារសម្រាប់សហគមន៍ខ្មែរទុក សម្រាប់ការឃោសនាខែវិច្ឆិកា ដែល១ភាគនៃសហគមន៍នោះនិយាយថា"អេដ កេណ្ណឺឌី មិនចង់ទុកដំណែងជាសមាជិកក្រុមប្រឹក្សាក្រុងទៅឱ្យ ចៅ សុខារី ដែលជាមិត្តជិតស្និតខាង រ៉ាឌី ម៉ម មិនឱ្យចូលទៅសាលាក្រុងឡូវែលបានទេ"។

៣-បោះឆ្នោត"3rd. District US Congress" ដំណែងដែលកាន់ដោយលោកស្រី នីគីសុងហ្គាស មកទល់ថ្ងៃនេះ បេក្ខជន ដានីញ៉ែល កូហ៍ Daniel Koh (បានឆ្នោត១៣៦៩៩) នឹងឡូរីត្រាហាន Lori Trahan (បានឆ្នោត១៣៩៨៣) នៅមិនទាន់ទទួលការប្រកាសជាផ្លូវការថា"នរណាជាអ្នកឈ្នះ"នៅឡើយទេ ដោយសារលទ្ធផលទាំង២នាក់នៅកៀកគ្នាពេក នៅពេលរាប់ឆ្នោតចុងក្រោយបង្អស់ដោយសាលាក្រុង9រាប់ឆ្នោតជាលើកទី២ (ឡូរី ត្រាហាន ឃើញឈ្នះ ដានីញ៉ែល កូហ ១២២សន្លឹក, តែនៅលើលទ្ធផលនោះ បេក្ខជន ដានីញ៉ែល កូហ៍ នៅមិនទាន់ទទួលយកនៅឡើយទេ ហើយបានធ្វើឱ្យរដ្ឋលេខាធិការក្រសួងរាប់សន្លឹកឆ្នោតប្រកាសយកហិបឆ្នោតទាំងអស់នោះទៅរាប់ខ្លួនឯងវិញ ព្រមទាំងសន្យាថានឹងផ្តល់លទ្ធផលនាការបោះឆ្នោតនេះ នៅមុនថ្ងៃទី១៧ កញ្ញា។

រីឯលទ្ធផលបន្តបន្ទាប់គឺ ជូអាណា ម៉ាចាស់ (បាន១០៩៦៤) - រ៉ូហ្វីស គីហ្វីដ (បាន៨៩៥៤) -បាបារ៉ា លីថាលិយ៉ាន (បាន៨៧៤២) -អាឡិសសង់ ឆានលី (បាន៣៧០២) -បូផា ម៉ាឡូន (បាន១១២៦) -ប៊ី ដាស (បាន១០៧៧) - ជេថ្វ បាលីន ជ័រ (បាន១០៦៤) -ឡេអូណា គោលដឺ (បាន ៤៥៩)

តាមការសង្កេតរបស់សាធារណជន គេយល់ថាសហគមន៍ខ្មែរ នឹងសហគមន៍ជនជាតិភាគតិចនៅតែមិនបានចេញទៅបោះឆ្នោតឱ្យបានច្រើន ទៅតាមភារកិច្ចជាពលរដ្ឋសេរីអាមេរិកាំង នៅឡើយទេ។


ដំណោះស្រាយការឱ្យខ្ចី
សម្រាប់លំនៅដ្ឋាន



តើលោក-អ្នកកំពុងរកទិញផ្ទះ ឬបង់សារជាថ្មីឡើងវិញនៅក្នុងរដ្ឋ Massachusetts ឬ New Hampshire ឬទេ? ក្រុមយើងដែលមានការជកពិសោធន៍នឹងណែនាំលោក-អ្នកឆ្លងកាត់ដំណើរការ ពីការស្វែងរក ជម្រើសការសុំខ្ចីប្រាក់រហូតដល់ដំណាក់ការបិទឯកសារចុងក្រោយបំផុត។ ការសម្រេចចិត្តដោយមិនបាច់ ទៅណាឆ្ងាយផ្តល់ឱ្យយើងឆ្លើយតប និងផ្តល់ដំណោះស្រាយអោយបានឆាប់រហ័ស និងមានប្រសិទ្ធិភាព។

អង្គភាពឱ្យខ្ចីប្រាក់ទិញផ្ទះ
នៅធានាគារអេនធ័រប្រាយ្ស៍
978-656-5653 | 877-671-2265
ដាក់ពាក្យសុំតាមអនឡាញនៅ EnterpriseBanking.com/Mortgage

យើងមានកម្មវិធី និងសេវាកម្មដែលសមរម្យនឹងសេចក្តីត្រូវការខ្ចីប្រាក់ របស់លោក-អ្នក។

ការដាក់ពាក្យអនឡាញមានភាពងាយស្រួល!

Enterprise Bank
CREATE SUCCESS

Member FDIC

EQUAL HOUSING LENDER

EnterpriseBanking.com/Mortgage

# បើប្រៀបធៀបកម្ពុជាបច្ចុប្បន្នទៅនឹងរបប"ប៉ុល ពត"

**ដោយ សុងធុល ហ្វៃណង់ដេស ប្រែសម្រួលពីភាសាបារាំងដោយខ្មែរផុសស.រ.អា.**

"រស់នៅជាពាណិជ្ជករតូចតាច គឺរង់ចាំតែស្លាប់ ហើយអរគុណគេដែលបានវាយក្បាលនឹងដងចប"នេះគឺជាការប្រៀបធៀបជីវភាពជាអាជីវករខាងទេសចរបច្ចុប្បន្នទៅនឹងនយោបាយនៃសម័យមួយដែលកម្ពុជាធ្លាប់ស្គាល់ នៅពេលដែល សុងធុល ទើបមកដល់ស្រុកបារាំងមិនទាន់បាន១ថ្ងៃផង ។ មហាមិត្រចិនបានមកវិនិយោគនៅកម្ពុជាក្នុងក៏រីតលេខមួយ តែគ្មានផលិតផលណាមួយបានចែកចាយដល់ផលប្រយោជន៍អាជីវករខ្មែរនោះទេ។

ទេសចរចិនរាប់ពាន់ម៉ឺននាក់ បានមកលេង"អង្គរវត្ត"ស្រុកខ្មែរ នាំប្រាក់ចំណូលតាំងពី១០=២០ ឥឡូវ៣៧ដុល្លា ចូលថវិការដ្ឋសន្ទឹកសន្ធាប់ដល់ហិបប្រាក់រដ្ឋ... ប៉ុន្តែប្រាក់ចាយវាយនៅកម្ពុជានៃទេសចរទាំងនោះ បែរជាហូរទៅតែអាជីវករចិនដែលធ្វើអាជីវកម្មបិទទ្វារក្នុងកម្ពុជា ដូចជា "ម៉ាសា" ចំណីអាហារ រថយន្តឈ្នួល ផ្ទះសំណាក់ សំបុត្រយន្តហោះ សូម្បីតែរបាំខ្មែរក៏វាមិនមើលផង... គឺមិនឱ្យប្រាក់ដុល្លាទាំងនោះធ្លាក់មកដល់ដៃអាជីករខ្មែរនោះទេ ។ អរគុណណាស់ដែលមហាមិត្រចិននាំទេសចររបៀបនេះមកស្រុកខ្មែរ!!!

ចិនបានវិនិយោគលើអាគិច្រើនជាន់ខ្ពស់ៗ វិនិយោគលើដីសង់បូរី ឬវីឡា លក់ក្នុងតម្លៃលក់ចេញខ្ពស់ តើខ្មែរប៉ុន្មាននាក់ដែលអាចទិញផ្ទះបូរីឬវីឡាទាំងនោះបាន? គឺគេលក់ផ្ទះរាប់ម៉ឺនខ្នងទៅឱ្យភ្ញៀវចិនគ្នាគេ ដែលចាំទីញផ្ទះនៅកម្ពុជាទាំងនោះ ក្នុងតម្លៃថោកសម្រាប់គេពីប្រទេសរបស់


សុងធុល ហ្វៃណង់ដេស

គេមក គឺគេនាំប្រជាជនចិនឱ្យមករស់នៅកម្ពុជាកាន់តែច្រើនឡើងជាលំដាប់... កោះកុង កំពុងសោមពោរពេញទៅដោយចិនរបៀបនោះ ដែលពេលខ្លះសុងធុលនិយាយថា"ខ្ញុំចង់ទៅហូបមីមួយចាននៅកំពង់សោមប្រទះសុទ្ធតែហាងដែលចេះតែអក្សរចិននិយាយភាសាចិនតែមួយមុខ ហើយគេលក់មីនៅស្រុកខ្មែរ..."ខ្មែររកហូបមីក្នុងស្រុកខ្លួនឯងមិនបានទេ... អរគុណណាស់លោកចិន ដែលបានមកវិនិយោគនៅស្រុកខ្មែរ!!!

គ្មានថ្ងៃណាមួយ ដែលគ្មានកាសែតចុះអត្ថបទពី"ចិនវាយខ្មែរ"នោះទេ...ចិនរកស៊ីកាក់កបនៅស្រុកខ្មែរពីព្រោះភ្ញៀវរបស់គេផលិតផលរបស់គេនៅក្នុងផ្សារបិទទ្វាររបស់គេ... ខ្មែរជាអ្នកក្រផ្តល់ទីកន្លែងថ្មីឱ្យចិនរកស៊ី បានត្រូវគេជះលុយមកឱ្យខ្មែរខ្ចី រួចហើយបែរជាគេទុកឱ្យស្លាប់ ដោយរកស៊ីមិនបាន-គ្មានរដ្ឋាភិបាលណាមើលឃើញហើយការពារផលប្រយោជន៍ជនជាតិឯងនោះទេ ...ប្រព័ន្ធធានាគារខ្មែរ ឱ្យខ្ចីលុយ ដោយគ្មានជួយនយោបាយការពារភ្ញៀវជាជនជាតិខ្លួននោះទេ ម្ល៉ោះហើយការរឹបអូសយកដីរឺបយកផ្ទះសម្បែង ក្លាយជាការងាយស្រួល នៅពេលមានអ្នកទាល់ច្រក មកខ្ចីប្រាក់នៅធានាគាម្តងៗ... អ្នករងគ្រោះខំការពារសម្បត្តិដែលសែសសល់ម្ចាស់បំណុលសង្ខើញទារប្រាក់ដែល"ការប្រាក់"ស្ទើរចុងស្ទើរដើម ក៏បង្ករជាជម្លោះសង្គមអស់សង្ឃឹមនឹងជីវិត...គ្មានទីបញ្ចប់...បើស្លាប់ទៅវិញ ក៏មិនអាក្រក់អ្វីដែរ។

ពីមុនមក គ្មាននរណានឹកដល់ ថាមហាមិត្រ-ចិន នឹងមកស្វែងរកលាភសក្ការអ្វីនៅប្រទេសដ៏តូចដូចជាកម្ពុជានោះទេ ប៉ុន្តែចិនពេលនេះបានប្តូរយុទ្ធសាស្ត្រ ទៅជាមហាអំណាចឈ្លានពានប្រទេសតូចៗជាច្រើនយ៉ាងគ្មានប្រណី រួចមកហើយ វាតទីតាំងបញ្ចេញដើមទុនទិញដូរមន្ត្រីឱ្យការពារប្រយោជន៍ចិន ដោយមិនដឹងខ្លួន។ សម្តេចសុីហានុ បន្ទាប់មកលោកហ៊ុន សែន បានធ្លាក់ក្នុងកលល្បិចរបស់ចិននោះ ប្រកបដោយជំនឿផ្តាប់មុខ ទៅលើមេដឹកនាំប្រទេសចិនទាំងអស់នោះ រហូតដល់ភ្លេចគិតថា "ពលរដ្ឋអាចនឹងបះបោរ នៅពេលអត់ទ្រាំនឹងការខូចខាតប្រយោជន៍ខ្មែរធំហួសប្រមាណ"មិនបាន។

ទប់ទល់នឹងគ្រោះថ្នាក់ដល់អំណាចការពារចិនរបស់រដ្ឋ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពង្រឹងអំណាចដោយរំលាយបក្សប្រឆាំងចោល, ចាប់អ្នកនយោបាយប្រឆាំងដាក់គុក, រំលាយបំណងចង់ប្រឆាំងផ្ទៃក្នុងដោយដាក់មន្ត្រីចាស់ៗឱ្យចូលនិវត្តន៍, ដាក់អ្នកឯកទេសសន្តិសុខសង្គមឱ្យកាន់កងទ័ព, ដាក់មនុស្សទុកចិត្តបំផុតរបស់ខ្លួន ឱ្យអមកាន់អំណាចជាមួយអ្នកទុកចិត្តតិចតួច...ទាំងនេះជាផ្ទូរនៃការរក្សាអំណាចឱ្យនៅខាងប្រទេសចិន ហើយបន្តដង្ហៀបនយោបាយកុម្មុយនិស្ត ដូចដែលធ្លាប់បានធ្វើ កាលពីទសវត្ស១៩៧៥-៧៩។

សុងធុល បានធ្វើការពិចារណាទៅរកតួនាទីរបស់មេទ័ពកំពូលដែលទើបនឹងប្តូរពីដៃលោក ប៉ុល សារឿន ដែលជាទាហ៊ានអ្នកចប្បាំងមកដៃលោក សៅ សុខា ជាមេទ័ព"ប៉េអិម"ជំនាញខាងរក្សាសន្តិសុខសង្គម គឺទំនងជាមានបំណងទប់ទល់វិបត្តិផ្ទៃក្នុង ច្រើនជាងចម្បាំងរាំងជល់នឹងបរទេស - ដោយគិតថា"ទំហុំនៃការខឹងសម្បាររបស់ពលររដ្ឋអាចនឹងធំធេងជាងការធ្វើបាតុកម្មអហឹង្សាទៀតផង" ពេលនោះហើយដែលលោក ហ៊ុន សែន ត្រូវការទាហ៊ានសន្តិសុខសង្គមនោះឯង។

សុងធុល បានគិតទៀតថា"បក្សប្រឆាំងបានត្រូវគេបំបាក់ស្មារតីបាន ពីព្រោះនៅចំពោះមុខវិបត្តិដ៏ធំធេងមួយ ដែលគេរំលាយគណបក្សសង្គ្រោះជាតិគាំទ្រដោយប្រជាពលរដ្ឋកន្លះនគរចោល បែរជានាំគ្នារត់ចេញពីស្រុកអស់ដែលធ្វើឱ្យប្រជាពលរដ្ឋខកចិត្តមិនតិចទៅវិញទេ- គឺមិនគួរធ្វើយ៉ាងនេះសោះ ដោយហេតុថា គេ"ធ្វើនយោបាយ គឺប្រកបដោយជំនឿ" សូមមើល "អូនសាំងស៊ូជី"គេមិនបានចេញពិភូមាទេ គេនៅតស៊ូ រហូតដល់ការទុកចិត្តរបស់ពលរដ្ឋនាំឱ្យគេឈ្នះបាន...បក្សប្រឆាំងខ្មែរយើងមិនបាននាំគ្នានៅតស៊ូជាមួយពលរដ្ឋទេ។

ក្នុងបរិយាកាសគៀបសង្កត់ឱ្យគោរពយួននឹងចិន ដែលបានក្លាយជាសត្រូវប្រជាជាតិគោរពអ្វីដែលខ្មែរស្អប់ខ្ពើម, រាស្ត្រខ្មែរនៅសល់តែការអស់សង្ឃឹមថា"ស្លាប់នឹងប្រសើរឬជាងរស់នៅ..." អ្នកនាំឱ្យមានការតស៊ូក្នុងប្រទេសក៏ចេញអស់ពីប្រទេស... អស់ភាពកក់ក្តៅសម្រាប់កំដរជីវិតខ្មែរបច្ចុប្បន្ន នឹងបានយល់ម្តងទៀតថា "ហេតុអ្វីក៏ជំនាន់ប៉ុលពត គេរីករាយនឹងឱនក្បាលឱ្យគេវាយនឹងដងចប.... ជាជាងបន្តរស់នៅ" នោះ។




# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING




### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

***Khmer Post USA Distribution Locations Include:***

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2018 PRINTING DATES | 2018 PRINTING DATES |
|---|---|
| Jan 8 and 22 | July 9 and 23 |
| Feb 5 and 19 | Aug 6 and 20 |
| Mar 5 and 19 | Sept 10 and 24 |
| Apr 9 and 23 | Oct 8 and 22 |
| May 7 and 21 | Nov 5 and 19 |
| Jun 4 and 18 | Dec 3 and 17 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues)<br>5% Savings | 6 Months (12 Issues)<br>7.5% Savings | 12 Months (24 Issues)<br>10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

**45 Merrimack Street • Suite 218A • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

CELEBRATING 10 YEARS

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*